# បរិយាយប័ណ្ណឱសថ
# អាល់ហ្គូរ៉ែន ព្យូរតាមសរសៃឈាម
## ALGORENS

**I រូបភាពឱសថ** :

-ជាឱសថប្រភេទសូលុយស្យុងសំរាប់ចាក់ព្យូរតាមសរសៃឈាម

-១ប្រអប់មាន ១ដបប្លាស្ទិកចំណុះ 100ml

**II សមាសធាតុផ្សំ** : ក្នុង 100ml មាន៖

-Paracetamol………………1000mg

**III គុណភាពព្យាបាល** :

ឱសថនេះជាប្រភេទសូលុយស្យុងសំរាប់ចាក់ព្យូរតាមសរសៃឈាមប្រើព្យាបាលក្នុងរយៈពេលខ្លីសំរាប់បំបាត់ការឈឺចាប់កំរិតមធ្យម ជាពិសេសក្រោយ ពេលវះកាត់ និងបញ្ចុះកំដៅ។

**IV ការហាមប្រើ** :

ឱសថនេះហាមប្រើចំពោះលក្ខខណ្ឌដូចខាងក្រោម៖

-ចំពោះអ្នកងាយមានប្រតិកម្មជាមួយនឹង Paracetamol ឬជាមួយនឹងសារធាតុផ្សំណាមួយនៃឱសថនេះ។

-ចំពោះអ្នកមានជំងឺខ្វះគ្រាប់ឈាមក្រហម

-ចំពោះកូនក្មេងអាយុក្រោម១ឆ្នាំ

**V ការប្រុងប្រយ័ត្ន** :

ឱសថនេះត្រូវប្រុងប្រយ័ត្នចំពោះលក្ខខណ្ឌដូចខាងក្រោម៖

-ចំពោះអ្នកមានជំងឺខ្វះគ្រាប់ឈាមក្រហម

-ចំពោះអ្នកមានជំងឺខ្សោយតំរងនោមធ្ងន់ធ្ងរ (creatinine < 30ml/min)

-ចំពោះអ្នកញៀនស្រារ៉ាំរ៉ៃ

-ចំពោះអ្នកមានបញ្ហាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ

-មិនត្រូវផឹកស្រាអំឡុងពេលប្រើឱសថនេះទេ

-មិនត្រូវប្រើឱសថនេះលើសកំរិតណែនាំ

-មិនត្រូវប្រើឱសថហួសកាលបរិច្ឆេទប្រើប្រាស់

-ចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន៖ ការប្រើឱសថនេះចំពោះស្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះកូនត្រូវមានការណែនាំពីគ្រូពេទ្យ។

**VI ផលរំខានរួមមាន** :

-ផលរំខានទូទៅ (កំរកើតមាន)៖ អស់កម្លាំង ងាយមានប្រតិកម្ម

-វិបត្តិសរសៃឈាមបេះដូង (កំរកើតមាន)៖ សំពាធឈាមថយចុះ

-វិបត្តិថ្លើម (កំរកើតមាន)៖ កើនឡើងកំរិតអង់ហ្ស៊ីមក្នុងថ្លើម

-វិបត្តិស្បែកនិងជាលិកាក្រោមស្បែក (កំរកើតមានបំផុត)៖ ប្រតិកម្មអាល្លែកហ្ស៊ីស្បែកធ្ងន់ធ្ងរ

-វិបត្តិគ្រាប់ឈាម (កំរកើតមានបំផុត)៖ ថយចុះចំនួនប្លាកែត កើនឡើងចំនួន neutrophils ក្នុងឈាម

➢ ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យ ប្រសិនបើមានផលរំខានណាមួយកើតឡើង។

**VII អន្តរកម្មឱសថ** :

គួរជៀសវាងប្រើរួមគ្នាជាមួយឱសថដូចខាងក្រោម៖

-Anticoagulants

-Hepatotoxic drugs/hepatic enzymes

-Probenecid

-Salicylamide

**VIII ការរក្សាទុក** :

-ត្រូវរក្សាទុកនៅសីតុណ្ហភាពក្រោម ៣០°C

-ត្រូវទុកកុំឲ្យត្រូវកំដៅថ្ងៃនិងសំណើម

-ត្រូវទុកឲ្យផុតពីដៃកូនក្មេង

-មិនត្រូវប្រើឱសថនេះទេប្រសិនបើសូលុយស្យុងក្នុងដបឡើងល្អក់ឬដបធ្លាយ

**IX ការប្រើហួសកំរិតណែនាំ** :

-ធ្វើឲ្យខូចកោសិការថ្លើមនិងអាចបណ្តាលឲ្យស្លាប់

**X កំរិតនិងរបៀបប្រើ** :

❖ **របៀបប្រើ៖**

-ឱសថនេះប្រើសំរាប់ចាក់ព្យូរតាមសរសៃឈាមយឺតៗក្នុងរយៈពេល១៥នាទី។

-ត្រូវទុកចន្លោះពេលប្រើអប្បបរមា៤ម៉ោងដាច់ពីគ្នា។

-មិនត្រូវប្រើឱសថនេះលើសពី៤ដងក្នុង១ថ្ងៃ។

❖ **កំរិតប្រើ៖**

-ចំពោះមនុស្សពេញវ័យនិងមនុស្សវ័យជំទង់ទម្ងន់លើសពី 50kg និងមិនមានហានិភ័យពុលថ្លើម៖ កំរិតណែនាំឲ្យប្រើគឺ1g (ស្មើនឹង100mlនៃសុលុយស្យុងថ្នាំ 10mg/ml) ហើយអាចបង្កើនកំរិតប្រើរហូតដល់ 4g ដែលជាកំរិតប្រើអតិបរិមា ក្នុង១ថ្ងៃ។

-ចំពោះមនុស្សពេញវ័យនិងមនុស្សវ័យជំទង់ទម្ងន់លើសពី 50kg និងមានហានិភ័យពុលថ្លើម៖ កំរិតណែនាំឲ្យប្រើគឺ1g (ស្មើនឹង100mlនៃសូលុយស្យុងថ្នាំ 10mg/ml) ហើយអាចបង្កើនកំរិតប្រើរហូតដល់ 3g ដែលជាកំរិតប្រើអតិបរិមាក្នុង១ថ្ងៃ។

-ចំពោះមនុស្សពេញវ័យទម្ងន់ក្រោម 50kg និងទម្ងន់លើសពី 33kg៖ កំរិតណែនាំឲ្យប្រើគឺ 15mg ក្នុងទម្ងន់ខ្លួន 1kg (ស្មើនឹង1.5mlនៃសូលុយស្យុងថ្នាំ 10mg/ml ក្នុងទម្ងន់ខ្លួន1kg) ។កំរិតប្រើអតិបរិមាប្រចាំថ្ងៃគឺមិនត្រូវលើសពី 60mg នៃ Paracetamol ក្នុងទម្ងន់ខ្លួន1kg ឬ 3g នៃ Paracetamol ក្នុង១ថ្ងៃ។

-ចំពោះកូនក្មេងទម្ងន់ចន្លោះពី 10kg ទៅ 33kg៖ កំរិតណែនាំឲ្យប្រើគឺ 15mg ក្នុងទម្ងន់ខ្លួន1kg (ស្មើនឹង1.5mlនៃសូលុយស្យុងថ្នាំ 10mg/ml ក្នុងទម្ងន់ខ្លួន1kg)។ កំរិតប្រើអតិបរិមាប្រចាំថ្ងៃគឺមិនត្រូវលើសពី 60mg នៃ Paracetamol ក្នុងទម្ងន់ខ្លួន 1kg ឬ 2g នៃ Paracetamol ក្នុង១ថ្ងៃ។

-ចំពោះទារកទម្ងន់ក្រោម10kg៖ កំរិតណែនាំឲ្យប្រើគឺ 7.5mg ក្នុងទម្ងន់ខ្លួន1kg (ស្មើនឹង0.75ml នៃសូលុយស្យុងថ្នាំ10mg/mlក្នុងទម្ងន់ខ្លួន1kg)។ កំរិតប្រើអតិបរិមាប្រចាំថ្ងៃគឺមិនត្រូវលើសពី 30mg នៃParacetamolក្នុងទម្ងន់ខ្លួន 1kg។

-កំរិតប្រើចំពោះអ្នកជំងឺខ្សោយតំរងនោមធ្ងន់ធ្ងរ៖ ប្រសិនបើកំរិត creatinine ក្នុងឈាមតិចជាងឬស្មើ 30ml/min ត្រូវទុកចន្លោះពេលប្រើ ៦ម៉ោង ដាច់ពីគ្នា។

➢ មុននឹងប្រើឱសថនេះ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ។

**XI លេខបញ្ជិកា** : CAM N0016IP-17

**XII ផលិតដោយ** : Abaris Healthcare Pvt. Ltd. (India)

បានបកប្រែនិងត្រួតពិនិត្យដោយនាយកដ្ឋានឱសថចំណីអាហារបរិក្ខារពេទ្យនិងគ្រឿងសំអាង។

លេខ:១៧៨៤/១៧ឱអបស ចុះថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ២០១៧